**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ១៥៨១ មស.សភរ

ថ្ងៃចន្ទ ៥ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០១៩

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធាន គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ៖** ស្តីពីសេចក្តីជូនដំណឹងដល់មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ចូលរួមប្រឡងគ្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ២០១៩ នៅសាលាភូមិន្ទរដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា នៅឆ្នាំ២០១៩នេះ សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំបើកវគ្គបណ្តុះបណ្តាលបន្តសម្រាប់មន្ត្រីរាជការស៊ីវិល យោធិន និងមន្ត្រីនគរបាលជាតិ ដែលរួមមានវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល វគ្គវិក្រឹត្យការមន្ត្រីមធ្យម និងវគ្គវិក្រឹត្យការមន្ត្រីក្រមការ។ វគ្គបណ្តុះបណ្តាលបន្តមានរយៈពេល៩ខែ ដែលក្នុងនោះរួមមានការសិក្សាទ្រឹស្តី ការអនុវត្តជាក់ស្តែង និងការអនុវត្តការងារសកម្មភាពសង្គម។ ដោយផ្អែកលើតម្រូវការ និងស្ថានភាពជាក់ស្តែងសម្រាប់ឆ្នាំ២០១៩នេះ សាលាភូមិន្ទរដ្ឋបាលបានកំណត់យកការបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់ចំនួន១៦០នាក់ (វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ចំនួន១២០នាក់ និងវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួន៤០នាក់) និងមន្ត្រីមធ្យមចំនួន៨០នាក់ (វគ្គវិក្រឹត្យការមន្ត្រីមធ្យមចំនួន៤០នាក់ និងវគ្គវិក្រឹត្យការមន្ត្រីក្រមការចំនួន៤០នាក់)។ ក្នុងន័យនេះ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ការចុះឈ្មោះរបស់មន្ត្រីរាជការ ចូលរួមប្រឡងគ្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩នាពេលខាងមុខនេះ គឺមិនមានការកំណត់ចំនួននោះទេ។

លក្ខណៈវិនិច្ឆ័យរបស់មន្ត្រីរាជការ ដែលអាចចុះឈ្មោះប្រឡងគ្រួតពិនិត្យសមត្ថភាពគឺមានដូចខាងក្រោម៖

**១)វគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់**

**ក)វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់**

- រដ្ឋបាលថ្នាក់ជាតិ ៖ មន្ត្រីរាជការស៊ីវិល យោធិន ឬមន្ត្រីនគរបាលជាតិកំពុងកាន់តំណែងចាប់ពីអនុប្រធាននាយកដ្ឋាន ឬមុខតំណែងប្រហាក់ប្រហែលឡើងទៅ (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការកំពុងកាន់តំណែងជាអភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលារាជធានី-ខេត្ត ប្រធានមន្ទីរជុំវិញរាជធានី-ខេត្ត ឬតំណែងប្រហាក់ប្រហែលឡើងទៅ (មិនមែនមន្ត្រីនយោបាយ មានឋានៈស្មើ)
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច៣ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ផ្លូវវេងអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ខ)វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល

- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ(ក) ព្រមទាំងយោធិន ឬមន្ត្រីនគរបាលមានឋានន្តរសក្តិចាប់ពីវរសេនីយ៍ឯកឡើងទៅ
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច៣ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

២)វគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម

ក)វគ្គវិក្រឹត្យការមន្ត្រីមធ្យម

- រដ្ឋបាលថ្នាក់ជាតិ ៖ មន្ត្រីរាជការស៊ីវិល យោធិន ឬមន្ត្រីនគរបាលជាតិកំពុងកាន់មុខតំណែងគ្រប់គ្រងចាប់ពីប្រធានការិយាល័យ ឬមុខតំណែងប្រហាក់ប្រហែលចុះក្រោម (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖មន្ត្រីរាជការកំពុងកាន់ក្នុងតំណែងជាអភិបាលរងក្រុង ស្រុក ខណ្ឌ នាយករងរដ្ឋបាលសាលារាជធានី-ខេត្ត អនុប្រធានមន្ទីរជុំវិញរាជធានី-ខេត្ត នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ឬមុខតំណែងប្រហាក់ប្រហែលចុះក្រោម (មិនមែនមន្ត្រីនយោបាយមាន ឋានៈស្មើ)
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច២ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ខ)វគ្គវិក្រឹត្យការមន្ត្រីក្រមការ

- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ(ខ) ព្រមទាំងយោធិន ឬមន្ត្រីនគរបាលជាតិមានឋានន្តរសក្តិក្រោមវរសេនីយ៍ឯក
- មន្ត្រីរាជការខាងលើ ត្រូវមានអតីតភាពការងារយ៉ាងតិច២ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

មន្ត្រីរាជការ ដែលមានគោលបំណងអភិវឌ្ឍសមត្ថភាពបន្ថែម អាចចូលរួមក្នុងការប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩ ដោយត្រូវបំពេញបែបបទតាមប្រព័ន្ធOnlineលើគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh និងត្រូវមានឯកសារភ្ជាប់ជាមួយដូចជា៖

១) ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស បញ្ជាក់ពីការចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋ

២)ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា ឬសេចក្តីសម្រេច បញ្ជាក់ពីការតែងតាំងក្នុងតំណែង (សម្រាប់វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គវិក្រឹត្យការមន្ត្រីមធ្យម)

៣)ប្រវត្តិរូបសង្ខេបបញ្ជាក់ដោយនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិករបស់ក្រសួង ស្ថាប័ន ឬប្រធានអង្គភាពគ្រប់គ្រងមន្ត្រីផ្ទាល់(អាចទាញយកតាមពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)

៤)លិខិតបង្ហាញហេតុ (Motivation Letter) របស់សាមីខ្លួន(អាចទាញយកតាមពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)

៥)សញ្ញាបត្រខ្ពស់ជាងគេ( ឧទាហរណ៍៖ សញ្ញាបត្របណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង)

ខ្ញុំសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា មន្ត្រីរាជការ ដែលមានបំណងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌនៃវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩នៅសាលាភូមិន្ទរដ្ឋបាលនឹងត្រូវអនុញ្ញាតឲ្យបំពេញបែបបទតាមប្រព័ន្ធ Online ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។ បន្ទាប់ពីបេក្ខជនបានប្រឡងជាប់ជាស្ថាពរ

សាលាកូមិន្ទរដ្ឋបាលនឹងរៀបចំលិខិតស្នើសុំការសម្រេចជាគោលការណ៍ឯកភាពពី**សម្តេច ឯកឧត្តម លោកជំទាវ** ដើម្បីផ្តល់ការអនុញ្ញាតឲ្យសាមីខ្លួនមកទទួលការបណ្តុះបណ្តាលបន្តក្នុងរយៈពេល៩ខែ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងមានចំណាត់ការដ៏ខ្ពង់ខ្ពស់តាមការគួរ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។ ៚

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សមាជិកក្រុមប្រឹក្សាសាលាកូមិន្ទរដ្ឋបាល
-ឯកសារ-កាលប្បវត្តិ

**សម្រាប់ព័ត៌មានបន្ថែម**
**សូមមេត្តាទំនាក់ទំនង៖** -០៧៧ ២៨៨ ៩៨៨
-០៨៩ ៨៥៥ ៥៥៥
-០៩៦ ៧៩ ៦៩ ៦៦១
-០៩៨ ៩៥៩ ៨៨៧